# ការវិភាគ និងអនុសាសន៍របស់

# ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (UNCT)

# លើសេចក្តីព្រាងវិសោធនកម្ម

# ច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)

*ថ្ងៃទី ២៦ ខែតុលា ឆ្នាំ ២០២៣*

*<u>បកប្រែក្រៅផ្លូវការ</u>*

មាតិកា


I. សេចក្តីផ្តើម

II. សារតារ

III. សេចក្តីសង្កេត និងអនុសាសន៍

ក) មុខងារនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក
ខ) ការចុះបញ្ជីជាកាតព្វកិច្ច
គ) ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការស្របច្បាប់
ឃ) ការរាយការណ៍
ង) ភាពមិនអនុលោម និងទោសទណ្ឌ

# I. សេចក្តីផ្តើម

១. ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានគូសបញ្ជាក់ជាថ្មីថា សិទ្ធិសេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី គឺជា “ធាតុផ្សំជាសារវន្តនៃលទ្ធិប្រជាធិបតេយ្យ ដោយបានផ្តល់ឱ្យបុគ្គលនានានូវឱកាសដ៏មានតម្លៃ ជាអាទិ៍ ដើម្បីសម្តែងមតិនយោបាយ ចូលរួមក្នុងការងារអក្សរសាស្ត្រ និងសិល្បៈ ព្រមទាំងសកម្មភាព វប្បធម៌ សេដ្ឋកិច្ច និងសង្គមដទៃទៀត ចូលរួមគោរពសាសនា ឬជំនឿផ្សេងទៀត បង្កើត និងចូលរួមក្នុងសហជីព និងសហករណ៍ និងបោះឆ្នោតជ្រើសរើសអ្នកដឹកនាំដើម្បីតំណាងឱ្យផលប្រយោជន៍របស់ពួកគេ ព្រមទាំងទាមទារគណនេយ្យភាពពីអ្នកដឹកនាំទាំងនោះ”។[1] ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក៏បាន “រំលឹកដល់រដ្ឋអំពីកាតព្វកិច្ចគោរព និងការពារឱ្យបានពេញលេញនូវសិទ្ធិរបស់បុគ្គលគ្រប់រូប... ក្នុងការបង្កើតសមាគមដោយសេរី តាមប្រព័ន្ធអនឡាញ (Online) និងអូហ្វឡាញ (Offline) រួមទាំងនៅក្នុងបរិបទនៃការបោះឆ្នោត រាប់បញ្ចូលទាំងបុគ្គលដែលមានគំនិត ឬជំនឿភាគតិច ឬជំទាស់ អ្នកការពារសិទ្ធិមនុស្ស សកម្មជនសហជីព និងបុគ្គលដទៃទៀត ដូចជា ជនទេសន្តរប្រវេសន៍ដែលមានបំណងចង់អនុវត្ត ឬលើកកម្ពស់សិទ្ធិនេះ និងត្រូវចាត់វិធានការចាំបាច់គ្រប់បែបយ៉ាង ដើម្បីធានាថាការរឹតត្បិតលើការអនុវត្តដោយសេរី នូវសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមដោយធ្វើឡើងស្របតាមកាតព្វកិច្ចរបស់ខ្លួននៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។”[2]

២. កាលពីខែសីហា ឆ្នាំ ២០១៥ ការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា បានផ្តល់នូវការវិភាគជាទូទៅមួយទៅលើ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ហៅកាត់ថា LANGO)[3] ក្នុងគោលបំណងដើម្បីជួយដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាថា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះ គោរពតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ជាដើម។[4]

៣. កំណត់វិភាគដែលរៀបចំដោយក្រុមអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (UNCT) ធ្វើឡើងផ្អែកតាមបញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល[5] បច្ចុប្បន្ន និងផ្អែកតាមសេចក្តីព្រាងវិសោធនកម្មដែលស្នើឡើងដោយរាជរដ្ឋាភិបាល ដែលមានកាលបរិច្ឆេទ ថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០២២។ ការវិភាគនេះក៏

---

1 សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ១៥/២១ បុព្វកថា។

2 សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ២៤/៥ កថាខណ្ឌទី ២។

3 កាលពីខែសីហា ឆ្នាំ ២០១៥ ការិយាល័យ OHCHR នៅកម្ពុជា បានរៀបចំ និងចែករំលែកការវិភាគជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដែលជាការរួមចំណែកដល់ការពិចារណា និងការអនុម័តលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល - https://cambodia.ohchr.org/sites/default/files/OHCHR_analysis_of_5th_LANGO_Eng.pdf.

4 លើកពីនេះ សេរីភាពនៃការបង្កើតសមាគម មានចែងនៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (មាត្រា ២០) កតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (មាត្រា ៥) អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (មាត្រា ៧) និងអនុសញ្ញាស្តីពីសិទ្ធិកុមារ (មាត្រា ១៥) ជាដើម។

5 មាត្រា១, ៧, ៨, ៩, ១០, ១១, ២០, ២៤, ២៥, ២៦, ២៧, ៣០, ៣១, ៣២ និង៣៥ នៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល។

ពិចារណាលើអនុសាសន៍ជាក់លាក់ ដែលផ្តល់ដោយស្ថាប័នសន្ធិសញ្ញា និងនីតិវិធីពិសេស ជាពិសេស សេចក្តីសង្កេតសន្និដ្ឋានលើរបាយការណ៍តាមកាលកំណត់លើកទី៣ របស់ប្រទេសកម្ពុជា ដែលផ្តល់ដោយគណៈកម្មាធិការសិទ្ធិមនុស្ស កាលពីខែឧសភា ឆ្នាំ ២០២២[6] ដែលមានភាពពាក់ព័ន្ធនឹងការការពារសិទ្ធិសេរីភាពបង្កើតអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនៅប្រទេសកម្ពុជា។

## II. សាវតារ

៤. កាលពីខែឧសភា ឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ហេតុដូច្នេះ កម្ពុជាត្រូវអនុម័តច្បាប់ ឬវិធានការដទៃទៀតតាមការចាំបាច់ ដើម្បីផ្តល់សុពលភាពដល់សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញានេះ ដូចជា សិទ្ធិសេរីភាពសម្តែងការយល់ឃើញ សេរីភាពបញ្ចេញមតិ និងសេរីភាពក្នុងការបង្កើតសមាគម ព្រមទាំងសិទ្ធិចូលរួមនៅក្នុងកិច្ចការសាធារណៈជាដើម។[7]

៥. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាសិទ្ធិរបស់ពលរដ្ឋខ្មែរ ដើម្បីមានសេរីភាពបង្កើតសមាគម និងចូលរួមក្នុងអង្គការមហាជន ដើម្បីជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម។[8] រដ្ឋធម្មនុញ្ញក៏ទទួលស្គាល់កាតព្វកិច្ចអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចជា កតិកាសញ្ញា និងសន្ធិសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារជាដើម។[9] ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញបានធ្វើការបកស្រាយថា កាតព្វកិច្ចទាំងនេះ គឺជាផ្នែកនៃច្បាប់ក្នុងស្រុក និងអាចអនុវត្តផ្ទាល់នៅក្នុងប្រព័ន្ធតុលាការរបស់កម្ពុជា។

៦. ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ នៅថ្ងៃទី ១២ ខែសីហា ឆ្នាំ ២០១៥។ ច្បាប់នេះមានគោលបំណងការពារសិទ្ធិសេរីភាព ក្នុងការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[10] ច្បាប់នេះមានគោលបំណងកំណត់បែបបទដល់

---

6 CCPR/C/KHM/CO/3.

7 ICCPR, មាត្រា ២, ១៩, ២១-២២ និង ២៥។

8 រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤២។

9 Ibid, art. 31.

10 ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មាត្រា ១។

សមាគម[11] និងអង្គការមិនមែនរដ្ឋាភិបាល[12] នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[13] "សមាគមក្នុងស្រុក" ត្រូវបានឱ្យនិយមន័យថាជា អង្គការសមាជិកភាព ដែលត្រូវបានបង្កើតឡើងដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងគោលបំណងធ្វើជាតំណាង និងការពារផលប្រយោជន៍របស់សមាជិកខ្លួនដោយមិនទាញយកចំណេញ។ ចំណែកឯ "អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក" ត្រូវបានឱ្យនិយមន័យថាជា អង្គការមិនមែនសមាជិកភាព រួមទាំងការមូលនិធិ ដែលត្រូវបានបង្កើតឡើង ដោយរូបវន្តបុគ្គល និង/ឬនីតិបុគ្គល ក្នុងគោលបំណងផ្តល់មូលនិធិ និងសេវាលើវិស័យមួយ ឬច្រើន ដើម្បីផលប្រយោជន៍សាធារណៈ ដោយមិនទាញយកចំណេញ ឬមិនយកកម្រៃមកចែកគ្នា។[14]

៧. បើតាមព័ត៌មានដែលផ្តល់ដោយអតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សម្តេចក្រឡាហោម ស ខេង មានសមាគមចំនួន ២.៦២៣ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៤៨៦ បានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ គិតត្រឹមខែធ្នូ ឆ្នាំ២០២២។[15] គិតត្រឹមខែឧសភា ឆ្នាំ២០២៣ មានអង្គការមិនមែនរដ្ឋាភិបាលបរទេសចំនួន៣៤១ ដែលបានអនុស្សរណៈនៅមានសុពលភាពជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។[16]

---

11 បើតាមមាត្រា ៤ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល *អង្គការមិនមែនរដ្ឋាភិបាល* សំដៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សំដៅដល់ "*អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក*" ខណៈពេលដែលអង្គការមិនមែនរដ្ឋាភិបាល ដែលបង្កើតឡើងក្រៅព្រះរាជាណាចក្រកម្ពុជា សំដៅដល់ "*អង្គការមិនមែនរដ្ឋាភិបាលបរទេស*"។

12 បើតាមមាត្រា ៤ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល *អង្គការមិនមែនរដ្ឋាភិបាល* សំដៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សំដៅដល់ "*អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក*" ខណៈពេលដែលអង្គការមិនមែនរដ្ឋាភិបាល ដែលបង្កើតឡើងក្រៅព្រះរាជាណាចក្រកម្ពុជា សំដៅដល់ "*អង្គការមិនមែនរដ្ឋាភិបាលបរទេស*"។

13 មាត្រា ៣។

14 មាត្រា ៤។

15 សុន្ទរកថានៅក្នុងវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី ៥ (CSOs) នៅថ្ងៃទី ១២ ខែមករា ឆ្នាំ ២០២៣។ សម្រាប់ព័ត៌មានបន្ថែម https://www.khmertimeskh.com/501218514/over-6100-associations-and-ngos-recorded-in-cambodia-as-of-december-2022/ [ចូលមើលចុងក្រោយនៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០២៣]។

16 សូមមើល៖ https://www.mfaic.gov.kh/Page/2021-02-10-List-of-Foreign-NGOs-Which-Signed-MoU-with-the-Ministry-of-Foreign-Affairs-and-International-Cooperation [ចូលមើលចុងក្រោយនៅថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០២៣]។

៨. នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០១៩ អង្គការសង្គមស៊ីវិលចំនួន៥០០ បានស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ និងធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។[17] រាជរដ្ឋាភិបាលកម្ពុជា[18] បានផ្តើមដំណើរការពិនិត្យ និងពិភាក្សាសេចក្តីព្រាងវិសោធនកម្មលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដោយបានបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាលមួយ[19] ដែលមានភារកិច្ចធ្វើការពិគ្រោះយោបល់ជាមួយតំណាងអង្គការសង្គមស៊ីវិលលើខ្លឹមសារវិសោធនកម្មដែលត្រូវបានស្នើឡើងនេះ។

៩. នៅចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១៩ ដល់ខែកក្កដា ឆ្នាំ២០២០ ក្រុមការងាររាជរដ្ឋាភិបាលនេះបានរៀបចំកិច្ចពិភាក្សាពិគ្រោះយោបល់ចំនួន ៦លើក ជាមួយតំណាងអង្គការសង្គមស៊ីវិល។ បន្ទាប់ពីកិច្ចពិភាក្សាទាំងនេះ អង្គការសង្គមស៊ីវិលបានស្នើសុំឱ្យធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះមាត្រាចំនួន ១៥។[20] កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ ក្រុមការងាររបស់រាជរដ្ឋាភិបាល បានចែករំលែកសេចក្តីព្រាងវិសោធនកម្មដែលលើកស្នើឡើងដោយរដ្ឋាភិបាល[21] និងបានអញ្ជើញឱ្យតំណាងអង្គការសង្គមស៊ីវិលចូលរួមក្នុងការពិភាក្សាអំពីខ្លឹមសារនៃបញ្ញត្តិមាត្រាច្បាប់ដែលត្រូវបានលើកស្នើសម្រាប់ធ្វើវិសោធនកម្ម។ ចាប់តាំងពីការពិភាក្សាចុងក្រោយនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០២២ មក ពុំទាន់មានការឯកភាពចុងក្រោយរវាងក្រុមការងាររបស់រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលទៅលើខ្លឹមសារវិសោធនកម្មដែលស្នើឡើងសម្រាប់បញ្ញត្តិទាំងនេះនៅឡើយ។[22] នាពេលបច្ចុប្បន្ននេះ សេចក្តីព្រាងវិសោធនកម្មនេះ កំពុងត្រូវបានពិនិត្យដោយក្រុមការងាររបស់រាជរដ្ឋាភិបាល មុននឹងដាក់ឆ្លងកិច្ចពិគ្រោះយោបល់បន្ថែមទៀត។

---

17 សេចក្តីថ្លែងការណ៍រួមស្តីពីលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់លើសំណើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ថ្ងៃទី៦ ខែកក្កដា ឆ្នាំ ២០២០ អាចរកបានតាមរយៈគេហទំព័រ www.cpp.org.kh/details/212379។ លើសពីនេះ សូមមើលសេចក្តីប្រកាសរួម ដោយអំពាវនាវឱ្យមានការពន្លឿន និងការផ្តល់ឱកាសឱ្យអង្គការសង្គមស៊ីវិលបន្តចូលរួមក្នុងដំណើរការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០ អាចរកបានតាមរយៈ https://www.khmerkromngo.org/wp-content/uploads/2020/08/COMFREL-LANGO-ENG.pdf

18 សម្តេចក្រឡាហោម ស ខេង អតីតឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានផ្តល់ភ្លើងខៀវឱ្យមានការធ្វើវិសោធនកម្មច្បាប់នេះ ក្នុងអំឡុងវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល កាលពីខែកញ្ញា ឆ្នាំ ២០១៩។

19 ក្រុមការងារនេះមានសមាសភាពជាតំណាងមកពីក្រសួងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ដូចជា ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ។ ក្រុមការងារនេះមានឯកឧត្តម ប៊ុន ហុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាប្រធាន។

20 បទប្បញ្ញត្តិនៃមាត្រា ១, ៧, ៨, ៩, ១០, ១១, ២០, ២៤, ២៥, ២៦, ២៧, ៣០, ៣១, ៣២ និង ៣៥។ អង្គការសង្គមស៊ីវិលបានស្នើឱ្យធ្វើវិសោធនកម្មខ្លឹមសារនៅក្នុងមាត្រាចំនួន១២ ក្នុងចំណោមមាត្រាទាំងនេះ និងលុបចោលមាត្រា ២៤ និង ៣២។ ខ្លឹមសារលម្អិតនៃមាត្រាចំនួន ១៥ ដែលអង្គការសង្គមស៊ីវិលស្នើឱ្យធ្វើវិសោធនកម្មមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ។

21 ជាការឆ្លើយតបចំពោះសំណើរបស់អង្គការសង្គមស៊ីវិល ក្រុមការងាររាជរដ្ឋាភិបាលបានបូកសរុបជាតុចូល និងរៀបចំនូវសេចក្តីព្រាងវិសោធនកម្មបញ្ញត្តិច្បាប់ដែលមាន ១៦ មាត្រា ដូចជាមាត្រា ១, ៧, ៨, ៩, ១០, ១១, ២០, ២១, ២៤, ២៥, ២៦, ៣០, ៣១, ៣២, ៣៥ និង ៣៦។ ខ្លឹមសារលម្អិតនៃមាត្រាដែលត្រូវបានធ្វើវិសោធនកម្មទាំង ១៦ ដែលស្នើដោយរាជរដ្ឋាភិបាលមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ។

22 បើតាមសេចក្តីប្រកាសរួមដែលអំពាវនាវឱ្យមានការពន្លឿន និងការផ្តល់ឱកាសឱ្យអង្គការសង្គមស៊ីវិលបន្តចូលរួមនៅក្នុងដំណើរការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០២០។

## III. សេចក្តីសង្កេត និងអនុសាសន៍

១០. សេចក្តីសង្កេត និងអនុសាសន៍ ដែលបង្ហាញជូននៅក្នុងឯកសារនេះ គឺលទ្ធផលនៃការពិភាក្សា ក្នុងក្របខ័ណ្ឌក្រុមពិនិត្យឡើងវិញរបស់ក្រុមការងារអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (UNCT)។ សេចក្តីសង្កេត និងអនុសាសន៍ទាំងនេះ មានគោលបំណងផ្តល់យោបល់បច្ចេកទេសជូនរាជរដ្ឋាភិបាល ស្របតាមកាតព្វកិច្ចនៃសិទ្ធិអន្តរជាតិរបស់កម្ពុជា ជាអាទិ៍ កាតព្វកិច្ចពាក់ព័ន្ធនឹងការធានាសិទ្ធិសេរីភាពបង្កើតសមាគម ហើយទន្ទឹមគ្នាក៏ពិចារណាអំពីទំនាក់ទំនងជាមួយសិទ្ធិមនុស្សដទៃទៀត ដូចជា សិទ្ធិសេរីភាពសំដែងការយល់ឃើញ បញ្ចេញមតិ ប្រមូលផ្តុំដោយសន្តិវិធី និងចូលរួមក្នុងកិច្ចការសាធារណៈ។

១១. ការវិភាគលើមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងវិសោធនកម្មដែលស្នើឡើង និងអនុសាសន៍ពាក់ព័ន្ធ ត្រូវបានបែងចែកទៅតាមប្រធានបទរង ដូចតទៅ៖

ក) មុខងារនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក
ខ) ការចុះបញ្ជីជាកាតព្វកិច្ច
គ) ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការស្របច្បាប់
ឃ) ការរាយការណ៍
ង) ភាពមិនអនុលោម និងទោសទណ្ឌ

### ក) មុខងារនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

១២. មាត្រា ២៤ នៃសេចក្តីព្រាងវិសោធនកម្ម ចែងថា "*អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវរក្សាអព្យាក្រឹត្យភាពចំពោះគណបក្សនយោបាយ និងមិនត្រូវធ្វើសកម្មភាពនយោបាយអ្វីឡើយ។*" មាត្រា ៣០ និង ៣៣ នៃសេចក្តីព្រាងវិសោធនកម្មផ្តល់អំណាចឱ្យរាជរដ្ឋាភិបាល[23] ចេញលិខិតព្រមាន ព្យួរជាបណ្តោះអាសន្ន និងលុបការចុះបញ្ជីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយណា ដែលមិនគោរពតាមមាត្រា ២៤ នេះ។

១៣. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ធានាសិទ្ធិសេរីភាពបង្កើតសមាគម សំដែងការយល់ឃើញ បញ្ចេញមតិ ប្រមូលផ្តុំដោយសន្តិវិធី និងចូលរួមក្នុងកិច្ចការសាធារណៈ ក្រោមកម្មវត្ថុនៃការកំហិតដែលបានបញ្ជាក់តែប៉ុណ្ណោះ។ មាត្រា ២២ ទទួលស្គាល់សិទ្ធិសេរីភាពបង្កើតសមាគម ដែលអាចរឹតត្បិតបាន លុំកមានចែងនៅក្នុងច្បាប់ និងមានភាពចាំបាច់តម្រូវ នៅក្នុងសង្គមប្រជាធិបតេយ្យសម្រាប់គោលបំណងជាក់លាក់មួយចំនួន

---

[23] ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ប៉ុណ្ណោះ។ មាត្រា ១៩ (១) ការពារសិទ្ធិសំដែងការយល់ឃើញ ដោយពុំមានការជ្រៀតជ្រែក, សិទ្ធិនេះមិនស្ថិតនៅក្រោមកម្មវត្ថុនៃការដាក់កំហិតអ្វីនោះឡើយ ហើយក៏រាប់បញ្ចូលការយល់ឃើញដែលមានលក្ខណៈនយោបាយផងដែរ។[24] មាត្រា ១៩ (២) ធានាសិទ្ធិសេរីភាពបញ្ចេញមតិ ដែលរាប់បញ្ចូល "សេរីភាពក្នុងស្វែងរក ទទួល និងផ្តល់ព័ត៌មាន និងគំនិតគ្រប់ប្រភេទទាំងអស់"។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានបញ្ជាក់ថា សេរីភាពបញ្ចេញមតិគ្របដណ្តប់លើការជជែកវែកញែករឿងនយោបាយ ការផ្តល់យោបល់លើកិច្ចការផ្ទាល់ខ្លួន និងលើកិច្ចការសាធារណៈ និងការពិភាក្សាអំពីសិទ្ធិមនុស្សនានា។[25] លើសពីនេះ ខណៈពេលដែលសេរីភាពក្នុងការបញ្ចេញមតិអាចត្រូវបានកំហិត លុះត្រាតែមានចែងនៅក្នុងច្បាប់ និងដែលចាំបាច់សម្រាប់ផ្នែកដែលត្រូវដាក់កំហិតចំនួន ២ គឺថា ការដាក់កំហិតទាំងនេះត្រូវមានលក្ខណៈសមាមាត្រ និងមិនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិនេះឡើយ។ ជាពិសេស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផ្តល់តម្លៃខ្ពស់ជាពិសេសដល់ការបញ្ចេញមតិដោយពុំមានការហាមប្រាម "នៅពេលដែលមានការជជែកវែកញែកជាសាធារណៈអំពីតួអង្គនៅក្នុងវិស័យសាធារណៈ និងនយោបាយ។"[26] គណៈកម្មាធិការសិទ្ធិមនុស្សក៏បានបានបញ្ជាក់ថា សេរីភាពបញ្ចេញមតិ ប្រមូលផ្តុំ និងបង្កើតសមាគម គឺជាលក្ខខណ្ឌជាសារវន្តសម្រាប់ការអនុវត្តសិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ និងការបោះឆ្នោតប្រកបដោយប្រសិទ្ធភាព ដោយមានកិច្ចការពារពីមាត្រា ២៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ជាពិសេស សិទ្ធិសេរីភាពបង្កើតសមាគម រាប់បញ្ចូល "សិទ្ធិសេរីភាពបង្កើត និងចូលរួមក្នុងអង្គការ និងសមាគម ដែលធ្វើការងារពាក់ព័ន្ធនឹងកិច្ចការនយោបាយ និងសាធារណៈ" ដែលមានទំនាក់ទំនងជាសារវន្តជាមួយសិទ្ធិដែលទទួលបានកិច្ចការពារពីមាត្រា ២៥។[27]

១៤. មាត្រា ២៤ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានស្នើធ្វើវិសោធនកម្ម បញ្ជាក់ថា អង្គការមិនមែនរដ្ឋាភិបាល និងសមាគមបរទេស "*ត្រូវរក្សាអព្យាក្រឹត្យភាពចំពោះគណបក្សនយោបាយ.... និងមិនត្រូវធ្វើសកម្មភាពនយោបាយឡើយ*"។ ពាក្យពេចន៍នេះដាក់កំហិតដោយផ្ទាល់លើសិទ្ធិបង្កើតសមាគម ដែលធ្វើការងារពាក់ព័ន្ធនឹងកិច្ចការនយោបាយ និងកិច្ចការសាធារណៈ។ ដូច្នេះ វាប៉ះពាល់ដល់សិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពបង្កើតសមាគម និងចូលរួមក្នុងកិច្ចការសាធារណៈ ដូចដែលត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

***<u>អនុសាសន៍</u>***

១៥. សូមលុបចោល**មាត្រា ២៤** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាភាពអនុលោមរបស់ច្បាប់នេះ ស្របតាមមាត្រា ១៩ ២២ និង ២៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ពាក្យថា "*អព្យាក្រឹត្យភាពនយោបាយ*" និង "*សកម្មភាពនយោបាយ*" ដែលចែងនៅក្នុងមាត្រា ២៤ ពុំមានសង្គតិ

---

[24] សូមមើលយោបល់ទូទៅលេខ ៣៤ កថាខ័ណ្ឌ ៩-១០ នៃគណៈកម្មាធិការសិទ្ធិមនុស្ស។

[25] យោបល់ទូទៅលេខ ៣៤ កថាខ័ណ្ឌ ១១ នៃគណៈកម្មាធិការសិទ្ធិមនុស្ស។

[26] Ibid, កថាខ័ណ្ឌ ៣៨។

[27] យោបល់ទូទៅលេខ ២៥ កថាខ័ណ្ឌ ៨ ១២ និង ២៦ នៃគណៈកម្មាធិការសិទ្ធិមនុស្ស។

ភាពជាមួយការធានាសិទ្ធិសេរីភាពបញ្ចេញមតិ សេរីភាពនៃការបង្កើតសមាគម និងការចូលរួមក្នុងកិច្ចការសាធារណៈ ដែលត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនោះឡើយ។

## ខ) ការចុះបញ្ជីជាកាតព្វកិច្ច

១៦. ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចែងពីនីតិវិធី និងលក្ខខណ្ឌសម្រាប់ការចុះបញ្ជីជាកាតព្វកិច្ចរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស។ មាត្រា ៦ តម្រូវឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវចុះបញ្ជីនៅក្រសួងមហាផ្ទៃ ហើយមាត្រា ១២ តម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវចុះបញ្ជីជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមទម្រង់ជាការចុះអនុស្សរណៈ (MoU)។ សេចក្តីព្រាងវិសោធនកម្មមាត្រា ៨ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចែងថា ក្រសួងមហាផ្ទៃត្រូវពិនិត្យលើឯកសារពាក្យសុំរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសម្រេចថាតើត្រូវទទួលយក ឬបដិសេធមិនចុះបញ្ជីឱ្យក្នុងអំឡុងរយៈពេល ៤៥ ថ្ងៃធ្វើការ ឬក្នុងករណីដែលតម្រូវឱ្យមានការកែតម្រូវនៅក្នុងពាក្យសុំ ក្នុងអំឡុងរយៈពេល ១៥ ថ្ងៃ។ ក្នុងករណី ក្រសួងមហាផ្ទៃមិនបានធ្វើការសម្រេចចិត្តក្នុងអំឡុងរយៈពេល ៤៥ ថ្ងៃ និង ១៥ ថ្ងៃខាងលើ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវចាត់ទុកថាបានចុះបញ្ជី។ មាត្រានេះចែងថា ក្រសួងមហាផ្ទៃអាចបដិសេធក្នុងការចុះបញ្ជីឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលមានគោលបំណង និងគោលដៅ "បង្កគ្រោះថ្នាក់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ" ហើយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានបដិសេធចុះបញ្ជីឱ្យមានសិទ្ធិប្តឹងទៅសាលាឧទ្ធរណ៍។

១៧. មាត្រា ៩ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចែងថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនឹងក្លាយជានីតិបុគ្គល ចាប់ពីថ្ងៃដែលក្រសួងមហាផ្ទៃបានចុះបញ្ជី។ មាត្រានេះចែងបន្តទៀតថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាដែលមិនបានចុះបញ្ជី នឹងមិនត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។

១៨. មាត្រា ៣២ នៃសេចក្តីព្រាងវិសោធនកម្មច្បាប់នេះ អនុញ្ញាតឱ្យអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការ ដើម្បីបញ្ឈប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ពីសកម្មភាពនានាជាបន្ទាន់ និងដាក់ទោស រួមនឹងការពិន័យ ក្នុងករណីមានមិនរាងចោលជាដើម[28] ហើយ ក្នុងករណីនៅតែបន្តធ្វើសកម្មភាពទៀត នឹងមានការប្តឹងទៅតុលាការ ដើម្បីចាត់វិធានការច្បាប់ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត"។ លើសពីនេះ មាត្រា ៣០ នៃសេចក្តីព្រាងវិសោធនកម្មច្បាប់ កំណត់ទុកជាស្រេចនូវកាលៈទេសៈ

[28] ក្រសួងមហាផ្ទៃអាចផាកពិន័យចន្លោះ ៥.០០០.០០០ រៀលដល់ ១០.០០០.០០០ រៀល ក្នុងករណីមិនរាងចាលអាជ្ញាធរមានសមត្ថកិច្ចត្រូវដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ដើម្បីចាត់វិធានការច្បាប់ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត។ បញ្ញត្តិនេះក៏អនុវត្តចំពោះសមាគម ឬអង្គការមិនរដ្ឋាភិបាលក្នុងស្រុកទាំងឡាយដែល ក្រសួងមហាផ្ទៃបានដកបញ្ជិកា ឬព្យួរសកម្មភាព ប៉ុន្តែនៅបន្តធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជា។

ដែលក្រសួងមហាផ្ទៃ ត្រូវលុបឈ្មោះចេញពីបញ្ជីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលរាប់បញ្ចូលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងឡាយណា "ដែលធ្វើសកម្មភាព ដែលអាចបង្កគ្រោះថ្នាក់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ"។

១៩. ពាក់ព័ន្ធនឹងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសវិញ មាត្រា ៣៤ ចែងថាអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ "ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណា ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬ ដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយវិធានការបន្ថែមទាក់ទងនឹងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ ដែលអាចត្រូវយកមកអនុវត្ត ។ មាត្រា ៣៥ នៃសំណើវិសោធនកម្មចែងថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពនៃអនុស្សរណៈ នៅពេលដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស "ខកខានមិនបានគោរពតាមអនុស្សរណៈនេះឱ្យបានត្រឹមត្រូវ" ឬក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសធ្វើសកម្មភាពដែលបង្កគ្រោះថ្នាក់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ"។

២០. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ក្នុងការមានសេរីភាពបង្កើតសមាគម រួមគ្នាជាមួយអ្នកដទៃទៀត និងចែងយ៉ាងច្បាស់ថា "គេមិនអាចដាក់កំហិតលើការអនុវត្តសិទ្ធិនេះ ក្រៅពីអ្វីដែលមានចែងនៅក្នុងច្បាប់ និងដែលចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ កិច្ចការពារសុខភាពសាធារណៈ ឬសីលធម៌ ឬកិច្ចការពារសិទ្ធិរបស់អ្នកដទៃ"។[29] ទោះបីជារដ្ឋអាចដាក់ចេញច្បាប់កំហិតសេរីភាពក្នុងការបង្កើតសមាគមក៏ដោយ ស្តង់ដារដែលត្រូវបានផ្តល់ជាអនុសាសន៍ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ កំណត់ថា រដ្ឋត្រូវអនុវត្តប្រព័ន្ធ "ជូនដំណឹង" ឱ្យបានឆាប់រហ័ស ពោលគឺ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានចាត់ទុកជានីតិបុគ្គលភ្លាមៗ ក្រោយពេលដែលសមាគម ឬអង្គការទាំងនេះ បានផ្តល់ព័ត៌មានជាមូលដ្ឋានអំពីអត្ថិភាព ឬសកម្មភាពរបស់ខ្លួនជូនអាជ្ញាធររដ្ឋបាលដែលពាក់ព័ន្ធ។[30] របបដាក់លិខិតប្រកាស គួរអនុវត្តជាជាងរបបចុះបញ្ជី។ សិទ្ធិសេរីភាពបង្កើតសមាគមអនុវត្តស្មើភាពគ្នាចំពោះសមាគមដែលពុំបានចុះបញ្ជី ហើយសមាគម គួរត្រូវបានគេសន្មតថាដំណើរការសកម្មភាពរបស់ខ្លួនដោយស្របច្បាប់ រហូតដល់ពេលដែលមានភស្តុតាងបង្ហាញផ្ទុយពីនេះ។[31]

២១. ក្នុងករណីដែលដំណើរការចុះបញ្ជីត្រូវបានដាក់ឱ្យអនុវត្ត តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការពារសិទ្ធិមនុស្សបានលើកជាអនុសាសន៍ថា ដំណើរការនេះគួរធ្វើឱ្យបានលឿន ដោយកំណត់រយៈពេលអប្បបរមាឱ្យបានខ្លី ដើម្បីឱ្យអាជ្ញាធរធ្វើការឆ្លើយតប ហើយការខកខានពុំបានផ្តល់ការឆ្លើយតបរហ័សនោះទេ បណ្តាលឱ្យអង្គការមិនមែនរដ្ឋាភិបាលនេះថា អាចដំណើរការបានដោយស្របច្បាប់។ លើសពីនេះ

---

[29] មាត្រា ២២.

[30] សូមមើល A/59/401 កថាខ័ណ្ឌ ៨២ (ខ)។ អភិក្រមនេះត្រូវបានផ្តល់ជាអនុសាសន៍ដោយអ្នករាយការណ៍ពិសេស ទទួលបន្ទុកសិទ្ធសេរីភាពប្រមូលផ្តុំដោយសន្តិវិធី និងសេរីភាពក្នុងការបង្កើតសមាគម៖ សូមមើល A/HRC/20/27 កថាខ័ណ្ឌ ៥៦-៦២ និង ៩៥-៩៦។

[31] សូមមើលរបាយការណ៍តំណាងពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកការពារសិទ្ធិមនុស្ស A/59/401 កថាខ័ណ្ឌ ៨២។

ស្ថាប័នចុះបញ្ជីឱ្យគួរមានលក្ខណៈឯករាជ្យពីរដ្ឋាភិបាល និងមានការចូលរួមពីតំណាងអង្គការសង្គមស៊ីវិលផង។ ការសម្រេចចិត្តមិនចុះបញ្ជី ត្រូវតែមានការពន្យល់ឱ្យបានពេញលេញ និងមិនអាចធ្វើឡើងដោយសារហេតុផលនយោបាយឡើយ ហើយក្នុងករណីដែលការខកខានមិនផ្តល់សេចក្តីពន្យល់ឱ្យបានលម្អិតអំពីការសម្រេចចិត្តនេះ អង្គការមិនមែនរដ្ឋាភិបាលនេះ គួរត្រូវបានចាត់ទុកថាអាចដំណើរការបានដោយស្របច្បាប់។[32]

២២. មាត្រា ៨ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលផ្តល់អំណាចតែមួយគត់ដល់ក្រសួងមហាផ្ទៃ ក្នុងការត្រួតពិនិត្យលើដំណើរការបង្កើត និងចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ លើសពីនេះ រយៈពេល ៤៥ ថ្ងៃ ដើម្បីសម្រេចលើសំណុំលិខិតស្នើសុំឱ្យចុះបញ្ជី គឺរយៈគឺជារយៈពេលមួយដ៏យូរ ដែលនៅក្នុងរយៈពេលនេះ សមាគម និងអង្គការមិនរដ្ឋាភិបាលត្រូវបានហាមប្រាមមិនឱ្យអនុវត្តសិទ្ធិសេរីភាពនៃការបង្កើតសមាគមរួចជាស្រេច។ ហេតុផលសម្រាប់ការបដិសេធចុះបញ្ជី ដែលមានចែងក្នុងមាត្រា ៨ នៃសេចក្តីព្រាងវិសោធនកម្មច្បាប់នេះ មានវិសាលភាពទូលំទូលាយជាងមូលហេតុ ដែលអាចអនុញ្ញាតឱ្យបានសម្រាប់ការរឹតត្បិតលើសិទ្ធិសេរីភាពបង្កើតសមាគម ដែលមានចែងក្នុងមាត្រា ២២ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ដូចដែលត្រូវបានលើកឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងករណីដែលមានការរឹតត្បិតលើសិទ្ធិ ដែលត្រូវបានទទួលស្គាល់ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "រដ្ឋត្រូវបង្ហាញពីភាពចាំបាច់នៃការដាក់កំហិតនេះ និងអាចចាត់វិធានការបែបនេះ ដែលសមាមាត្រទៅនឹងការសម្រេចគោលបំណងស្របច្បាប់ ដើម្បីជានាឱ្យមានការបន្តការពារសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញានេះប្រកបដោយប្រសិទ្ធភាព"។[33] ទោះជាក្នុងករណីណាក៏ដោយ គេមិនអាចអនុវត្តការដាក់កំហិត ដែលអាចអាចធ្វើឱ្យប៉ះពាល់ដល់សារៈសំខាន់នៃសិទ្ធិណាមួយដែលមានចែងនៅក្នុងកតិកាសញ្ញានេះឡើយ។ ដោយគ្រាន់តែលើកហេតុផលបែបសត្យានុម័ត ដើម្បីដាក់កំហិតលើសិទ្ធិសេរីភាពបង្កើតសមាគម នោះមិនគ្រប់គ្រាន់ឡើយ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពរបស់គណបក្សនយោបាយ។ រដ្ឋភាគីត្រូវបន្តបង្ហាញឱ្យឃើញថា ការហាមប្រាមសមាគមណាមួយ គឺចាំបាច់ ដើម្បីបញ្ចៀសការគំរាមកំហែងពិតប្រាកដ ពោលមិនមែនត្រឹមតែជាការគំរាមកំហែងក្នុងសម្មតិកម្ម ចំពោះសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់ប្រជាធិបតេយ្យ ថាវិធានការដែលមិនសូវជ្រៀតជ្រែក មិនមានភាពគ្រប់គ្រាន់ដើម្បីសម្រេចគោលបំណងខាងលើនេះ និងថា ការដាក់កំហិត គឺត្រូវតែមានលក្ខណៈសមាមាត្រទៅនឹងផលប្រយោជន៍ដែលត្រូវការពារ។"[34] អ្វីដែលសំខាន់ ការដាក់កំហិតដែលអាចអនុញ្ញាតឱ្យបានដូចមានចែងនៅក្នុងមាត្រា ២២ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនអាចប្រើប្រាស់ជាមធ្យោបាយដើម្បីរឹតត្បិតលើសមាគម ដែលជំទាស់នឹងគោលនយោបាយ ឬគោលជំហររបស់រដ្ឋឡើយ៖ "*ការលើកឡើងពីទស្សនទាន "សង្គមប្រជាធិបតេយ្យ" នៅក្នុងបរិបទនៃមាត្រា ២២ បង្ហាញថា..... អត្ថិភាព និងដំណើរការនៃ*

---

32 A/59/401, កថាខ័ណ្ឌ ៨២។

33 គណៈកម្មាធិការសិទ្ធិមនុស្ស យោបល់ទូទៅ លេខ ៣១ កថាខ័ណ្ឌ ៦។

34 Daher Ahmed Farah v. Djibouti (CCPR/C/130/D/3593/2019), para 7.3. and Raisa Mikhaillovskaya & Oleg Volchek v. Belarus (CCPR/C/111/D/1993/2010), para 7.3.

*សមាគម រួមទាំងសមាគមដែលផ្សព្វផ្សាយគំនិតផ្សេងៗដោយសន្តិវិធី ដែលរដ្ឋាភិបាល ឬប្រជាជនភាគច្រើនមិនមែនសុទ្ធតែគាំទ្រ និងអាចទទួលយកបាន គឺជាមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ*។[35]

២៣. ចំពោះការព្យួរ និងការបិទសមាគម និងអង្គការមិនមែនរដ្ឋាភិបាលវិញ មានការរឹតត្បិតសេរីភាពនៃការបង្កើតសមាគម ដែលមានលក្ខណៈធ្ងន់ធ្ងរបំផុត។ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិផ្តល់អនុសាសន៍ឱ្យអាជ្ញាធររដ្ឋាភិបាលមិនគួរមានអំណាចព្យួរសកម្មភាពទាំងនេះដោយទំនើងចិត្តនោះឡើយ។ អំណាចបែបនេះគួរតែអនុវត្ត ដោយតុលាការតែមួយប៉ុណ្ណោះ និងអាចអនុវត្តបានតែនៅក្នុងស្ថានភាពដែលគ្រោះថ្នាក់ជាក់ច្បាស់ប្រាកដជាកើតមានឡើង អាចនឹងបង្កឡើងដោយផ្ទាល់ដោយសារសកម្មភាពបែបនេះ និងពិតជាមានការបញ្ជាក់ផ្ទៀងផ្ទាត់ដោយសត្យានុម័ត ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ស្រដៀងគ្នានេះដែរ សកម្មភាពដែលធ្វើឡើងដោយរដ្ឋាភិបាលចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែសមាមាត្រ និងត្រូវជាកម្មវត្ថុនៃបណ្តឹងតវ៉ា និងការត្រួតពិនិត្យរបស់តុលាការ។[36]

## *<u>អនុសាសន៍</u>*

២៤.**ធ្វើវិសោធនកម្មមាត្រា ៦, ៨, ៩, ១១, ១២, ៣៤ និង ៣៥** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីព្រាងវិសោធនកម្មច្បាប់នេះ ឱ្យស្របតាមខ្លឹមសារនៃមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដូចជា៖

- គួរពិចារណាដាក់ឱ្យអនុវត្តនៅរបបជូនដំណឹង ដែលក្នុងនោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានចាត់ទុកថាជានីតិបុគ្គល ចាប់ពីថ្ងៃដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនេះបានជូនដំណឹងពីអត្ថិភាពរបស់ខ្លួន ជូនក្រសួងមហាផ្ទៃ តាមរយៈការផ្តល់ព័ត៌មានជាមូលដ្ឋាន ដូចជា ឈ្មោះ និងអាសយដ្ឋានរបស់ស្ថាបនិក ព្រមទាំងឈ្មោះ អាសយដ្ឋាន ស្ថានភាព និងគោលបំណងរបស់សមាគម ឬអង្គការនេះ។

- ប្រសិនបើប្រព័ន្ធចុះបញ្ជីត្រូវយកមកអនុវត្តន៍ នោះការចុះបញ្ជីនេះគួរត្រូវធ្វើឲ្យបានឆាប់រហ័ស ដូចជា ត្រូវផ្តល់ការចុះបញ្ជីឱ្យបានលឿន កំណត់រយៈពេលអប្បបរមាដែលអាជ្ញាធររដ្ឋត្រូវឆ្លើយតបឱ្យបានខ្លី មូលដ្ឋានដែលជាហេតុផលសម្រាប់ការបដិសេធការចុះបញ្ជី ដែលមិនអាចជាហេតុផលនយោបាយ គួរបញ្ជាក់ឱ្យបានច្បាស់នៅក្នុងច្បាប់ និងស្របតាមមាត្រា ២២ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ស្ថាប័នចុះបញ្ជី គួរតែមានលក្ខណៈឯករាជ្យពីរាជរដ្ឋាភិបាល និងត្រូវបានច្បាប់កំណត់កាតព្វកិច្ចឱ្យផ្តល់ការបញ្ជាក់លម្អិតជាលាយលក្ខណ៍អក្សរពីមូលហេតុសម្រាប់រាល់ការសម្រេចមិនចុះបញ្ជីទាំងអស់។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលត្រូវបានបដិសេធមិនចុះបញ្ជីឱ្យ គួរមាន

---

[35] *Korneenko v. Belarus* (CCPR/C/105/D/1226/2003), កថាខ័ណ្ឌ 10.3។

[36] A/59/401, កថាខ័ណ្ឌ 82(r)-(s); A/HRC/20/27, កថាខ័ណ្ឌ 75។

ឱកាសធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរ និងប្ដឹងតវ៉ាការសម្រេចនេះទៅកាន់ស្ថាប័នតុលាការដែលឯករាជ្យ។

- ស្នើសុំកែសម្រួល**កថាខណ្ឌ ៣ នៃមាត្រា ៨** ដើម្បីផ្ដល់ការបញ្ជាក់ឱ្យកាន់តែច្បាស់នៅក្នុងករណីដែលក្រសួងមហាផ្ទៃ ខកខានពុំបានធ្វើការសម្រេចចិត្តលើការចុះបញ្ជី ក្នុងរយៈពេលដែលបានកំណត់ និងអាចមិនអាចបានរៀបចំឯកសារដែលចាំបាច់ឱ្យបានភ្លាមៗ ដើម្បីផ្ដល់ភាពស្របច្បាប់ដល់ការចុះបញ្ជី។ ការធ្វើបែបនេះគឺដើម្បីឱ្យបញ្ញត្តិនេះមានសង្គតិភាពដែលជាមួយបញ្ញត្តិនៃមាត្រា ៩ ដែលចែងថា សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល នឹងក្លាយជានីតិបុគ្គល តែចាប់ពីថ្ងៃដែលត្រូវបានចុះបញ្ជីតែប៉ុណ្ណោះ។

## គ) ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការស្របច្បាប់

២៥.មាត្រា ២១ នៃសេចក្ដីព្រាងវិសោធនកម្មនេះចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជី ឬចុះអនុស្សរណៈ ត្រូវមានសិទ្ធិចុះកិច្ចសន្យាសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអនុវត្តសកម្មភាពរបស់ខ្លួន ស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

២៦.ទោះបីជាមាត្រា ២១ នៃសេចក្ដីព្រាងវិសោធនកម្មច្បាប់នេះ គូសបញ្ជាក់ជាថ្មីពីគោលការណ៍ជាមូលដ្ឋាននៃច្បាប់រដ្ឋប្បវេណី ដែលកំណត់ថា នីតិបុគ្គលអាចចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលសម្រាប់គោលបំណងស្របច្បាប់នានាក៏ដោយ ក៏មាត្រានេះហាក់បីជាដាក់កំហិតលើលទ្ធភាពចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ ដូចជាការផ្ដល់មូលនិធិគាំទ្រដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលរដ្ឋាភិបាលចាត់ទុកថាបានចុះបញ្ជីរួច។ អ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពប្រមូលផ្ដុំដោយសន្តិវិធី និងសេរីភាពបង្កើតសមាគម (SRFOAA) បានកត់សម្គាល់ថា លទ្ធភាពរបស់សមាគមក្នុងការទទួលបានថវិកាគាំទ្រ និងធនធាននានា គឺជាផ្នែកដ៏មានសារៈសំខាន់ជាសារវន្តនៃសិទ្ធិសេរីភាពបង្កើតសមាគម និងបានគូសបញ្ជាក់ថា "សមាគមទាំងឡាយ ទាំងបានចុះបញ្ជី ទាំងមិនបានចុះបញ្ជី គួរមានសិទ្ធិស្វែងរក និងទទួលបានការជានាមូលនិធិគាំទ្រ និងធនធានឱ្យពីស្ថាប័នក្នុងស្រុក បរទេស និងអន្តរជាតិ"។[37]

### *អនុសាសន៍*

២៧. សំណូមពរឱ្យមានការលុបចោល**មាត្រា ២១** នៃសេចក្ដីព្រាងវិសោធនកម្ម ដើម្បីធានាថា សមាគមទាំងអស់អាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ និងទទួលបានមូលនិធិគាំទ្រ ដែលជាផ្នែកដ៏សំខាន់នៃសិទ្ធិសេរីភាពបង្កើតសមាគម ស្របតាមខ្លឹមសារនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

---

[37] A/HRC/20/27, កថាខ័ណ្ឌ ៦៧-៦៨។

## ឃ) ការរាយការណ៍

២៨.មាត្រា ១០ តម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មាន រាល់គណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃចុះបញ្ជី។ លើសពីនេះ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធាន ឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ។ មាត្រា ២៥ នៃសេចក្តីព្រាងវិសោធនកម្ម កំណត់លក្ខខណ្ឌរាយការណ៍បន្ថែមទៀត សម្រាប់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដោយតម្រូវឱ្យអង្គការទាំងអស់ ផ្ញើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុក្នុងរយៈពេលកំណត់មួយ។ មាត្រានេះក៏ចែងផងដែរថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ អាចពិនិត្យ និងធ្វើសវនកម្មលើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមហាផ្ទៃ ឬ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

២៩.លើសពីនេះ មាត្រា ៣០ និង ៣៣ នៃសេចក្តីព្រាងវិសោធនកម្ម ចែងអំពីទោសទណ្ឌចំពោះការមិនគោរពតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១០ និង ២៥។ ទោសទណ្ឌទាំងនេះ រួមមានការព្យួរ ឬការលុបឈ្មោះចេញពីបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។

៣០. នៅក្នុងសេចក្តីសម្រេចលេខ ២២/៦ របស់ខ្លួន ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានអំពាវនាវឱ្យរដ្ឋជានាថា លក្ខខណ្ឌរាយការណ៍ "មិនអាចបន្ទុចបង្អាក់ដល់ស្វ័យភាពនៃការបំពេញការងារ" របស់សមាគម។ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហជាតិទទួលបន្ទុកការពារសិទ្ធិមនុស្ស បានលើកជាអនុសាសន៍ថា "ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល គួរដកចេញនូវសំណើដែលដាក់បន្ទុកលើសលប់ ដូចជា តម្រូវឱ្យដាក់ឯកសារដែលមិនចាំបាច់ជាដើម"។[38] អ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពប្រមូលផ្តុំដោយសន្តិវិធី និងសេរីភាពបង្កើតសមាគម ក៏បានបង្ហាញពីក្តីបារម្ភអំពីច្បាប់ទាំងឡាយដែលដាក់លក្ខខណ្ឌបន្តជាបន្ទុកដល់សមាគម និងដែលគំរាមកំហែងលុបចោលឈ្មោះចេញពីបញ្ជី ឬលែងឲ្យមានអត្ថិភាពស្របច្បាប់ ចំពោះការមិនអនុលោមទៅតាមលក្ខខណ្ឌទាំងនេះ។[39]

៣១.មាត្រា ១០ និង ២៥ ដាក់លក្ខខណ្ឌរាយការណ៍យ៉ាងច្រើនដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលបរទេសដែរ ដោយតម្រូវឱ្យអង្គការទាំងនេះផ្ញើព័ត៌មានអំពីគណនីធនាគារ សកម្មភាពប្រចាំថ្ងៃ របាយការណ៍ហិរញ្ញវត្ថុ ឯកសារគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញវត្ថុជាមួយអ្នកផ្តល់ជំនួយ ហើយក្នុងពេលជាមួយគ្នា ផ្តល់ធន្ទានុសិទ្ធិឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិ ធ្វើការពិនិត្យ

---

[38] A/59/401, កថាខ័ណ្ឌ 82(f)។

[39] A/HRC/38/34, កថាខ័ណ្ឌ 28។

និងផ្ទើសរនេកម្មសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ការចែងបែបនេះ គឺជាការពន្លាតលទ្ធភាពជ្រៀតជ្រែករបស់រដ្ឋាភិបាលលើសិទ្ធិសេរីភាពបង្កើតសមាគម។ លើសពីនេះ មាត្រា ៣០ និង ៣៣ ចែងពីការដាក់ទោសធ្ងន់ធ្ងរចំពោះការខកខានមិនបានគោរពតាមលក្ខខណ្ឌរាយការណ៍ ដែលក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរដែលមានជាអាទិ៍៖ ការលុបឈ្មោះចេញពីបញ្ជី ឬការផ្អាច់អនុស្សរណៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ជាដើម។ ដូចកត់សម្គាល់លើ កាព្យូរ និងការបិទដំណើរការ គឺជាការដាក់កំហិតយ៉ាងធ្ងន់ធ្ងរបំផុតលើសេរីភាពនៃការបង្កើតសមាគម ហើយ ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិតម្រូវថា មានតែតុលាការប៉ុណ្ណោះ ដែលគួរមានសិទ្ធិចេញបញ្ជាឱ្យមានការព្យួរ និងបានតែស្ថិតនៅក្នុងស្ថានភាពដែលប្រាកដប្រជាថានឹងមានគ្រោះថ្នាក់ជាក់លាក់កើតមានឡើងចេញដោយផ្ទាល់ពីសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដោយមានការបញ្ជាក់ផ្ទៀងផ្ទាត់ដោយសត្យានុម័ត។[40]

៣២.ចុងក្រោយ ដូចលើកឡើងលម្អិតខាងក្រោម មាត្រា ៣២ គំរាមពិន័យ ឬចាត់វិធានការច្បាប់ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី។ លក្ខខណ្ឌតម្រូវឱ្យរាយការណ៍ជាច្រើន ព្រមទាំងការគំរាមដាក់ទោសធ្ងន់ធ្ងរ គឺជាការបំពានសិទ្ធិសេរីភាពបង្កើតសមាគម ដែលត្រូវបានធានាដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ លើសពីនេះ ដូចដែលបានកត់សម្គាល់ដោយអ្នករាយការណ៍ពិសេសទទួលបន្ទុកសេរីភាពប្រមូលផ្តុំដោយសន្តិវិធី និងសេរីភាពបង្កើតសមាគម គឺថារបបច្បាប់បែបនេះអាចមាន "ឥទ្ធិពលបង្កអស្ថិរភាព និងគំរាមកំហែងដល់សមាគមនានា តាមរយៈការបង្កឱ្យមានការភាន់ច្រឡំ និងបង្កើនបន្ទុករដ្ឋបាលដល់ការបន្តអនុវត្តសកម្មភាពនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ហើយក្នុងពេលជាមួយគ្នានាំឱ្យសមាជិកនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលភ័យខ្លាចមិនហ៊ានធ្វើសកម្មភាព"[41] – ដែលការណ៍នេះនាំឱ្យមានប៉ះពាល់លើសេរីភាពជាមូលដ្ឋាន ដែលត្រូវបានការពារនៅក្រោមក្របខ័ណ្ឌនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

***<u>អនុសាសន៍</u>***

៣៣. សូមស្នើឲ្យធ្វើការកែសម្រួលខ្លឹមសារមាត្រាពាក់ព័ន្ធដូចខាងក្រោម៖

ក. គួរមានការកែសម្រួលខ្លឹមសារនៃ**មាត្រា ១០ និង ២៥** ដើម្បីធានាថា លក្ខខណ្ឌការរាយការណ៍មានលក្ខណៈសាមញ្ញ និងមិនដាក់បន្ទុកធ្ងន់ធ្ងរហួសហេតុ ដូចជា ការតម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដាក់ឯកសារដែលមិនចាំបាច់ជាដើម។

ខ. គួរកែសម្រួលខ្លឹមសារនៃ**មាត្រា ៣០ និង ៣៣** ដើម្បីដកអំណាចលុបឈ្មោះចេញពីបញ្ជី ឬបញ្ឈប់សកម្មភាពសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដោយអាជ្ញាធររដ្ឋ ហើយជំនួសមកវិញនូវអំណាចលុបឈ្មោះចេញពីបញ្ជី

---

[40] A/59/401, កថាខ័ណ្ឌ ៨២ (r)-(s); A/HRC/20/27, កថាខ័ណ្ឌ ៧៥។

[41] A/HRC/38/34, កថាខ័ណ្ឌ 28.

ឬបញ្ឈប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល គួរអនុវត្តដោយស្ថាប័នតុលាការ និងកំហិតត្រឹមតែចំពោះស្ថានភាពដែលប្រាកដប្រជាមានគ្រោះថ្នាក់ជាក់លាក់កើតមានឡើងបង្កដោយផ្ទាល់ពីសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដោយមានការពិនិត្យផ្ទៀងផ្ទាត់ជាសត្យានុម័ត ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

## ខ) ការមិនអនុលោម និងទោសទណ្ឌ

៣៤.ជំពូកទី ៧ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចែងអំពី "វិធានការ និងដាក់ទោសរដ្ឋបាល"។ ក្នុងជំពូកទី៧ មាត្រា ៣០ នៃសេចក្តីព្រាងវិសោធនកម្ម គឺអនុញ្ញាតឱ្យក្រសួងមហាផ្ទៃចេញលិខិតព្រមាន ព្យួរជាបណ្តោះអាសន្ន ឬលុបឈ្មោះចេញពីបញ្ជីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងករណីដែលមានភាពមិនអនុលោមផ្សេងៗតាមច្បាប់នេះ។ មាត្រា ៣២ ចែងថាអាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ។ មាត្រានេះក៏ចែងពីការពិន័យជាប្រាក់ ចន្លោះពី ៥ ទៅ ១០ លានរៀល "ក្នុងករណីមិនរាងចាល" ហើយដែលចែងថា ក្នុងករណីនៅតែបន្តធ្វើសកម្មភាពទៀត អាជ្ញាធរមានសមត្ថកិច្ច ត្រូវប្តឹងទៅតុលាការ ដើម្បីចាត់វិធានការតាមច្បាប់ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត។

៣៥.ស្រដៀងគ្នានេះដែរ មាត្រា ៣៥ ការចែងថា ក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស មិនអនុលោមតាមមាត្រា ២៤ ឬ ២៥ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ ហើយក្នុងករណីនៅតែបន្តមិនគោរពតាមច្បាប់នេះ និងមានការសម្រេចផ្តាច់សុពលភាពនៃអនុស្សរណៈ។

៣៦.មាត្រា ៣៤ ចែងថា អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ជាបន្ទាន់ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសណា ដែលធ្វើសកម្មភាពដោយមិនបានចុះបញ្ជី ឬដែលត្រូវបានបញ្ចប់សុពលភាពអនុស្សរណៈដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ វិធានការបន្ថែមទាក់ទងនឹងការបណ្តេញចេញស្របតាមច្បាប់អន្តោប្រវេសន៍ អាចត្រូវបានអនុវត្តចំពោះជនបរទេសណា ដែលបម្រើការងារនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលប្រព្រឹត្តល្មើសខាងលើ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត។

៣៧. លើសពីនេះ បើតាមមាត្រា ៣៥ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចបញ្ចប់សុពលភាពនៃអនុស្សរណៈក្នុងករណីដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អនុវត្តមិនបានត្រឹមត្រូវតាមអនុស្សរណៈដែលបានចុះជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្នុងករណី "ដែលសមាគម ឬអង្គ

ការមិនរដ្ឋាភិបាលបរទេស ធ្វើសកម្មភាពដែលប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ"។[42] ពាក្យថា 'សន្តិសុខសង្គម ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ' មិនទាន់ត្រូវបានកំណត់និយមន័យឲ្យបានច្បាស់លាស់នៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នេះឡើយ។

៣៨. ដូចដែលលើកឡើងដោយអ្នករាយការណ៍ពិសេសទទួលបន្ទុកខាងសេរីភាពខាងសមាគម លើកឡើងថា សិទ្ធិសេរីភាពបង្កើតសមាគម អនុវត្តចំពោះអាយុកាលទាំងស្រុងរបស់សមាគម ហើយការព្យួរ និងការរំលាយសមាគមដោយបង្ខំ គឺជាប្រភេទនៃការដាក់កំហិតធ្ងន់ធ្ងរបំផុតលើសេរីភាពនៃការបង្កើតសមាគម។ ការដាក់កំហិតដែលអាចអនុញ្ញាតឱ្យបាន គួរអនុវត្តតែនៅក្នុងករណីដែល "ប្រាកដប្រជាថាមានគ្រោះថ្នាក់ជាក់លាក់ ដោយសារការប្រព្រឹត្តល្មើសជាក់ស្តែងចំពោះច្បាប់ជាតិ និងអាចត្រូវអនុវត្តឱ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។[43] ការដាក់កំហិតទាំងនេះ គួរមានលក្ខណៈសមាមាត្របំផុត តាមគោលបំណងស្របច្បាប់ ដែលពាក់ព័ន្ធ និងប្រើប្រាស់ តែនៅក្នុងករណីដែលវិធានការទន់ភ្លន់ជាងនេះមិនមានភាពគ្រប់គ្រាន់តែប៉ុណ្ណោះ។ លើសពីនេះ ការដាក់កំហិតដោយសារ "មូលហេតុសណ្តាប់ធ្នាប់សាធារណៈ/សីលធម៌/ក្រមសីលធម៌" និងដោយសារលក្ខណៈវិនិច្ឆ័យដទៃទៀត ដែលមានគោលបំណងដាក់កំហិតលើសិទ្ធិបង្កើតសមាគមដោយសេរី ត្រូវតែមានការកំណត់និយមន័យឱ្យបានច្បាស់លាស់ ហើយត្រូវផាត់ចេញមានសកម្មភាពដែលពាក់ព័ន្ធសិទ្ធិមនុស្សនានា ចេញពីការដាក់កំហិតទាំងនេះ។[44] លើសពីនេះ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកការពារសិទ្ធិមនុស្ស បញ្ជាក់ថា "មិនគួរមានការផ្តល់អំណាចដល់អាជ្ញាធរ រដ្ឋាភិបាល ក្នុងការព្យួរ ឬរំលាយក្រុមសិទ្ធិមនុស្សដោយចិត្តឯងនោះឡើយ។ មានតែតុលាការប៉ុណ្ណោះដែលគួរមានអំណាចបញ្ជាឱ្យមានការព្យួរ និងតែនៅក្នុងករណីដែលប្រាកដប្រជាមានគ្រោះថ្នាក់ជាក់លាក់បង្កឡើងដោយផ្ទាល់ពីសកម្មភាពទាំងនេះ ដែលមានការបញ្ជាក់ផ្ទៀងផ្ទាត់ដោយសត្យានុម័ត និងគោរពតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ"។[45]

៣៩. វិធានការ និងទោសរដ្ឋបាលដែលបច្ចុប្បន្នត្រូវបានចែងនៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីព្រាងវិសោធនកម្មច្បាប់នេះ បំពានស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។ ទី ១ វិធានការ និងទោសទណ្ឌទាំងនេះអាចផ្ទុយនឹងគោលការណ៍ដែលកំណត់ថា ការចុះបញ្ជីសមាគម មិនគួរចាត់ទុកថាជាកាតព្វកិច្ចឡើយ។ ទី ២ ពាក្យពេចន៍ដែលប្រើប្រាស់បច្ចុប្បន្ននៅក្នុងមាត្រា ៣០ និង ៣៣ ផ្តល់អំណាចឱ្យក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (អាចទៅតាមករណីជាក់ស្តែង) ក្នុងការព្យួរ លុបឈ្មោះចេញពីបញ្ជី ឬបញ្ចប់សុពលភាពនៃអនុស្សរណៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ខណៈពេលដែលច្បាប់សិទ្ធិមនុស្ស

---

[42] ដើម្បីផ្អាក់អនុស្សរណៈរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលខកខានមិនបានផ្ញើរបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍ពីកិច្ចព្រមព្រៀងទទួលថវិកាទាំងអស់ ដូចជារបាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានដាក់ជូនអ្នកផ្តល់ជំនួយ ក្នុងអំឡុងរយៈពេល ៣០ ថ្ងៃប្រសិនបើសមាគម ឬអង្គការទាំងនេះ បានទទួលមូលនិធិគាំទ្រពីអ្នកផ្តល់ជំនួយ។ បញ្ញត្តិនេះក៏អនុវត្តផងដែរ ប្រសិនបើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ពុំបានអនុវត្តតាមលក្ខន្តិកៈរបស់ខ្លួនដែលត្រូវបានតម្កល់នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

[43] A/HRC/20/27, កថាខ័ណ្ឌ ៧៥

[44] A/59/401, កថាខ័ណ្ឌ ៨២ (o).

[45] Ibid, កថាខ័ណ្ឌ ៨២(r).

អន្តរជាតិ អំពាវនាវឱ្យមានការកំណត់ថា មានតែតុលាការប៉ុណ្ណោះ ដែលមានអំណាចបែបនេះ និងតែនៅក្នុងស្ថានភាពដែលប្រាកដប្រជាមានគ្រោះថ្នាក់ជាក់លាក់កើតឡើងបង្កដោយផ្ទាល់ពីសកម្មភាពរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ទី ៣ ពាក្យថា "សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ" មិនទាន់ត្រូវបានកំណត់និយមន័យឲ្យច្បាស់លាស់ ហើយមានវិសាលភាពទូលំទូលាយជាងការដាក់កំហិតដែលអនុញ្ញាតឱ្យបាន ដូចមានចែងក្នុងមាត្រា ២២ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ចុងក្រោយ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចែងពីការពិន័យជាប្រាក់ធ្ងន់ធ្ងរ ការចាត់វិធានការច្បាប់ និងការបណ្តេញចេញពលរដ្ឋនៃប្រទេសទី ៣ ដែលជាទោសទណ្ឌដ៏ធ្ងន់ធ្ងរ ដែលបង្កផលប៉ះពាល់ធ្ងន់ធ្ងរលើសេរីភាពជាមូលដ្ឋានដែលត្រូវបានការពារនៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ដូច្នេះ ទោសទណ្ឌដែលអាចអនុវត្តបាន គួរកំហិតទៅតាមកាលៈទេសៈ និងកំណត់ដោយស្ថាប័នតុលាការមានសមត្ថកិច្ច ស្របតាមគោលការណ៍នីត្យានុកូលភាព ភាពចាំបាច់ និងសមាមាត្រ។

## ***<u>អនុសាសន៍</u>***

៤០. គួរពិចារណាកែសម្រួលខ្លឹមសារនៃ**មាត្រា ៣០ ៣២ ៣៥ និង ៣៦** ដើម្បីធានាថា មាត្រាទាំងនេះស្របតាមមាត្រា ២២ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាពិសេស គឺថាមានតែស្ថាប័នតុលាការប៉ុណ្ណោះ ដែលមានអំណាចផ្តាច់មុខក្នុងការស៊ើបអង្កេត និងដាក់ទោសទណ្ឌលើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពល្មើស, ដកចេញ ឬកំណត់ឱ្យបានជាក់លាក់បំផុតនូវមូលហេតុដែលអាចនាំឱ្យមានការព្យួរ ឬការបញ្ឈប់សមាគម ឬអង្គការមែនរដ្ឋាភិបាល ដែលគួរកំណត់ឱ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងធានាថា ភាពមិនប្រក្រតីផ្នែករដ្ឋបាល ឬការផ្លាស់ប្តូរមិនសំខាន់របស់អង្គការណាមួយ មិនត្រូវបានចាត់ទុកថាជាមូលហេតុសមស្រប ដើម្បីព្យួរ ឬបញ្ឈប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលឡើយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលគួរ៖

ក. ពិចារណាលុបចោលមាត្រានៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលតម្រូវឱ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវចុះបញ្ជី ឬត្រូវមានអនុស្សរណៈដែលមានសុពលភាពមុនចាប់ផ្តើមដំណើរការសកម្មភាពរបស់ខ្លួន។

ខ. កែសម្រួលខ្លឹមសារនៃ**មាត្រា ៣០ ៣២ ៣៥ និង ៣៦** ដើម្បីដកចេញនូវអំណាច ព្យួរសមាគម និងអង្គការមិនមែនរដ្ឋាភិបាលតាមទំនើងចិត្តពីអាជ្ញាធររដ្ឋាភិបាល អំណាចព្យួរសមាគម និងអង្គការមិនរដ្ឋាភិបាល គួរផ្តល់ទៅឱ្យតុលាការដែលមានអំណាចផ្តាច់មុខក្នុងការស៊ើបអង្កេតលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលសង្ស័យថាបានបំពានច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា ក៏ដូចជា ចេញដីកាពិន័យជាប្រាក់ លុបឈ្មោះចេញពីបញ្ជី ឬបញ្ចប់អនុស្សរណៈនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បន្ទាប់ពីបានអនុវត្តដំណើរការត្រឹមត្រូវរួចមក។

គ. ពិចារណាកែសម្រួលខ្លឹមសារនៃមាត្រា ៣៥ ដើម្បីអនុញ្ញាតឱ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ផ្តួចផ្តើមការពិភាក្សាជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលពាក់ព័ន្ធ ដែលត្រូវបានរកឃើញថាកំពុងប្រតិបត្តិការមិនប្រក្រតី ក្នុងគោលបំណងកែតម្រូវភាពមិនប្រក្រតីទាំងនេះ។ ជាអនុសាសន៍ គួរបន្ថែមកិច្ចការពារផ្នែកនីតិវិធីជាក់លាក់នៅក្នុងមាត្រានេះ ដើម្បីអនុញ្ញាតឲ្យសមាគម និងអង្គការការមិនមែនរដ្ឋាភិបាលបរទេស អាចតវ៉ាការសម្រេចរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅកាន់ស្ថាប័នតុលាការមានសមត្ថកិច្ច។

ចប់.